# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

មជ្ឈមណ្ឌលអប់រំ
**440 N. Broad Street**
**Philadelphia, Pennsylvania 19130**
ការិយាល័យផ្នែក កម្មវិធីសិក្សា ការបង្ហាត់បង្រៀន និង ការវាយតម្លៃ

ព័ត៌មានស្ដីអំពីឯកសារនៃការប្រឡងដែលមិនប្រើពាក្យពេចន៍ *ណាហ្គ្លេរី* / Naglieri Nonverbal Assessment Test (NNAT)

គណកម្មាធិការកែទម្រង់សាលារៀនបានយល់ព្រមឲ្យទិញឯកសារនៃការប្រឡងដែលមិនប្រើពាក្យពេចន៍ ណាហ្គ្លេរី (Naglieri) (NNAT) សម្រាប់ឲ្យសិស្សថ្នាក់ទី២ទាំងអស់ប្រឡង នៅនិទាឃរដូវ ឆ្នាំ២០១៧ នេះ។ ឯកសារនេះនឹងជួយលោកអ្នកឲ្យដឹងថាតើ ការប្រឡងដែលមិនប្រើពាក្យពេចន៍ ណាហ្គ្លេរី គឺជាអ្វី ហើយថាតើគេនឹងប្រើឯកសារសម្រាប់ការប្រឡងនេះដើម្បីជួយដល់ការអប់រំរបស់កូនលោកអ្នកដោយវិធីណា។

**តើ ការប្រឡងដែលមិនប្រើពាក្យពេចន៍ *ណាហ្គ្លេរី* គឺជាអ្វី?**

ការប្រឡងដែលមិនប្រើពាក្យពេចន៍ *ណាហ្គ្លេរី* គឺជាការប្រឡងដែលប្រើរូបភាព ដូចជាការផ្គុំរូប (shape puzzles) និង លំនាំ (patterns) ជាជាងការប្រើពាក្យពេចន៍ ដើម្បីវាយតម្លៃចំណេះដឹងអ្វីមួយ។ មិនតម្រូវឲ្យអាន ឬនិយាយ អ្វីទេ។ ការវាយតម្លៃដែលមិនប្រើពាក្យពេចន៍នេះនឹងវាយតម្លៃពីសមត្ថភាពវិភាគ និងការដោះស្រាយបញ្ហាពិបាកៗ របស់កូនលោកអ្នក ដោយមិនពឹងផ្អែកទៅលើ ឬមិនគិតពីការមិនសូវចេះភាសា ឬសមត្ថភាពនៃការអាន។

**តើព័ត៌មាននេះនឹងប្រើដោយវិធីណា?**

គេនឹងប្រើព័ត៌មានដែលបានពី ការប្រឡងដែលមិនប្រើពាក្យពេចន៍ *ណាហ្គ្លេរី* ដើម្បីជួយគ្រូឲ្យដឹងកាន់តែច្រើនអំពីសមត្ថភាពរបស់កូនលោកអ្នក។ សមត្ថភាពដែលបានបិទបាំងដោយកត្តាផ្សេងៗ ដូចជាភាសាជាដើម។ វានឹងជួយអ្នកអប់រំទាំងអស់ដែលបង្រៀនកូនលោកអ្នក ឲ្យដឹងពីវិធីល្អបំផុតដែលកូនរបស់លោកអ្នកអាចរៀន។ នឹងមានច្បាប់ចម្លងនៃរបាយការណ៍របស់កូនលោកអ្នកមួយច្បាប់សម្រាប់លោកអ្នក។

**តើការប្រឡងនេះ អាចដឹងថាតើកូនខ្ញុំជាសិស្សឆ្លាតដែរឬទេ?**

អត់ទេ។ ការប្រឡងដែលមិនប្រើពាក្យពេចន៍ *ណាហ្គ្លេរី* តែមួយមុខ មិនអាចសម្រេចថាតើអ្នកណាឆ្លាត ឬមិនឆ្លាត បានទេ។ សិស្សដែលបានពិន្ទុកម្រិតខ្ពស់ ក្នុងការប្រឡង NNAT អាច ឬមិនអាច ជាសិស្សឆ្លាត។ ដូចគ្នានេះដែរ សិស្សដែលមិនបានពិន្ទុខ្ពស់ ក៏អាចជាសិស្សឆ្លាតដែរ។ NNAT បានបង្ហាញឲ្យដឹងថាវាជាវិធីដ៏ល្អ ដែលអាចឲ្យក្មេងទៅជាសិស្សឆ្លាត។ វានឹងក្លាយទៅជាផ្នែកមួយនៃប្រវត្តិទិន្នន័យរបស់កូនលោកអ្នក ហើយវាអាចជួយដល់ការពិនិត្យវាយតម្លៃរកសិស្សឆ្លាត។

**តើការប្រឡងនេះមានអ្វីខ្លះ?**

ការប្រឡងត្រូវចំណាយពេលប្រហែល៣០នាទី ហើយត្រូវធ្វើតាមអ៊ិនធ័រណិត។ សំណួរទាំង៣៨ គឺជាប្រភេទនៃ រូបភាព និង លំនាំ ខុសៗគ្នា។ ក្មេងវិភាគពី រូបភាព ឬ លំនាំ ហើយចុចលើរូបដែលបាត់ចន្លោះ។ សិស្សនឹងរួមគ្នាធ្វើជាក្រុម។

**តើអ្វីទៅជាវិធីល្អបំផុតដែលខ្ញុំអាចជួយកូនរបស់ខ្ញុំ?**

NNAT មិនមែនជាការប្រឡងដែលធ្លាប់ធ្វើពីមុនមកនោះទេ។ វាគឺជាការដោះស្រាយចំណោទរូបភាព។ បើសិនជាកូនរបស់លោកអ្នកមិនធ្លាប់មានបទពិសោធន៍ច្រើនជាមួយ ចំណោទរូបភាព ឬ លំនាំ ត្រូវឲ្យពួកគេរៀនធ្វើ និងរៀនពីវិធីដោះស្រាយ នេះគឺជាការត្រៀមខ្លួនដ៏ល្អបំផុត។

**តើខ្ញុំត្រូវទាក់ទងទៅអ្នកណា បើសិនជាខ្ញុំមានសំណួរ?**

សំណួរអាចផ្ញើតាមអ៊ីមែលទៅ gifted@philasd.org។